## ករុណា ការប្ដេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

# ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យកាល់ម៉ែត

## Calmette's Newsletter N° 08

ខែ តុលា ២០១៨ - ធ្នូ ២០១៨

ព្រឹត្តិបត្រលេខ ៨



រៀបចំដោយ

គណៈកម្មការទស្សនាវដ្ដីនៃមន្ទីរពេទ្យកាល់ម៉ែត

# ទំព័រផ្សេងៗ

ខែ តុលា ២០១៨ - ធ្នូ ២០១៨

ទស្សនាវដ្តីលេខ ៨


1 អភិវឌ្ឍន៍ — ប្រពន្ធ័ពត៌មានវិទ្យា មន្ទីរពេទ្យ

2 អភិវឌ្ឍន៍ — វគ្គបណ្តុះបណ្តាល ដល់ នាយសាល ជំនួយការនាយសាល គិលានុបដ្ឋាក-យិកា និងឆ្មប ស្តីពីការធ្វើអនាម័យដៃតាមអនឡាញ!

3 សុខភាព — តើលោកអ្នកដឹង ពីជំងឺគ្រុនពោះវៀន ឬទេ?

4 សុខភាព — តើជំងឺ ឈឺក-ឈឺចាក់ដល់ដៃ មានសភាពដូចម្តេចខ្លះ?

5 សុខភាព — គ្រោះថ្នាក់ធ្ងន់ធ្ងរនៃ គ្រួសតម្រងនោម!

6 សុខភាព — ជំងឺគ្រោះថ្នាក់សរសៃឈាម ខួរក្បាលអាចបណ្តាលឲ្យ យើងស្លាប់ ឬធ្លាក់ខ្លួនពិការ បាន (Stroke)!

7 សក្ខីភាព — ជំងឺស្ទះសរសៃវ៉ែន ខួរក្បាល!

8 សំនួរចម្លើយ — សំណួរចម្លើយ Quiz? ទាក់ទងនឹងសុខភាព



www.facebook.com/calmette.gov.kh

hospital@calmette.gov.kh

www.calmette.gov.kh







# ប្រព័ន្ធព័ត៌មានវិទ្យាមន្ទីរពេទ្យ



គឺជាប្រធានបទថ្មីមួយបន្ថែមទៀត ដែលត្រូវបានលើកយកមកក្នុងបទបង្ហាញក្នុងឱកាសសិក្ខាសាលានាថ្ងៃអង្គារ ០៩កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៨ ដែលបានរៀបចំ និងប្រព្រឹត្តទៅនៅមន្ទីរពេទ្យកាល់ម៉ែតនៃកម្ពុជា។

«ដំណោះស្រាយប្រព័ន្ធព័ត៌មានវិទ្យាមន្ទីរពេទ្យ (enjeux du système d'information hospitalier)» គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទបច្ចុប្បន្នភាពបំផុត ដែលជាបរិបទថ្មីមួយបន្ថែមទៀតសម្រាប់ការលើកយកមកសិក្សាស្វែងយល់ដោយស៊ីជម្រៅ ក្នុងទិសដៅរៀបចំខ្លួន និងត្រៀមលក្ខណៈសម្បត្តិឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការដាក់ឱ្យដំណើរការនូវប្រព័ន្ធនេះនៅតាមផ្នែកសេវាថែទាំ និងព្យាបាលនៃមន្ទីរពេទ្យ។

បទអន្តរាគមន៍លើប្រធានបទដ៏មានសារៈសំខាន់នេះត្រូវបានចូលរួមពីសំណាក់អ្នកជំនាញការពីររូបមកពីក្រុមបណ្តាញមន្ទីរពេទ្យក្រុងម៉ាកសី ប្រទេសបារាំង (Assistance publique des hôpitaux de Marseille) និងចូលរួមផ្លាស់ប្តូរគំនិតយោបល់ និងបទពិសោធន៍ពីគ្រប់កម្រិតនៃអ្នកទទួលខុសត្រូវនៃមន្ទីរពេទ្យកាល់ម៉ែតនៃកម្ពុជា។







# សិក្ខាសាលាស្តីពី "វេជ្ជសាស្ត្រនុយក្លេអ៊ែរ ឬវេជ្ជសាស្ត្រម៉ូលេគុលឡា"



នាព្រឹកថ្ងៃច័ន្ទ ១៣កើត ខែអស្សុជ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែ តុលា ឆ្នាំ២០១៨ មន្ទីរពេទ្យកាល់ម៉ែតមជ្ឈមណ្ឌលជាតិជំងឺមហារីក រួមសហការជាមួយភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ បានរៀបចំសិក្ខាសាលា ក្នុងគោលបំណងដើម្បីបង្ហាញជូននូវបច្ចុប្បន្នភាព នៃបច្ចេកវិទ្យាវិទ្យាសាស្ត្រម៉ូលេគុលឡា ព្រមទាំងបង្កើននូវចំណេះដឹង និងបទពិសោធន៍បន្ថែមពីអ្នកជំនាញនៃផ្នែកនេះ។

សិក្ខាសាលានេះ ផ្តោតសំខាន់ទៅលើ:

១- បច្ចុប្បន្នភាព នៃវេជ្ជសាស្ត្រនុយក្លេអ៊ែរ ឬម៉ូលេគុលឡានៅមជ្ឈមណ្ឌលជាតិជំងឺមហារីកនៃមន្ទីរពេទ្យកាល់ម៉ែត។



២- អត្ថប្រយោជន៍ នៃវេជ្ជសាស្ត្រម៉ូលេគុលឡា ក្នុងការព្យាបាលជំងឺមហារីកក្រពេញទីរ៉ូអ៊ីត និងជំងឺពុល ក្រពេញទីរ៉ូអ៊ីត។ លើសពីនេះទៅទៀត បច្ចេកវិទ្យាដ៏ទំនើប និងប្រសិទ្ធភាពខ្ពស់នេះ ក៏ប្រើប្រាស់ផងដែរក្នុងការធ្វើរោគវិនិច្ឆ័យជំងឺមួយចំនួន ( ឧ, ជំងឺក្រពេញទីរ៉ូអ៊ីត ជំងឺឆ្អឹង, ជំងឺស្ទះបំពង់បង្ហូរទឹកមូត្រ ...)។



«ជាលទ្ធផលនៃអង្គសិក្ខាសាលា គឺបាននាំមកនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗបន្ថែមអំពីបច្ចេកទេសដ៏ទំនើបនេះបន្ថែមលើជំនាញឯកទេសផ្សេងៗដទៃដែលមន្ទីរពេទ្យបាន និងកំពុងអភិវឌ្ឍន៍ស្រាប់ទាំងក្នុងការព្យាបាលជំងឺ និងការរករោគវិនិច្ឆ័យ។»

# តើលោកអ្នកដឹងពី ជំងឺគ្រុនពោះវៀន ឬទេ ?



ដែលអាចគំរាមគំហែងដល់អាយុជីវិតរបស់អ្នកជំងឺបាន ប្រសិនបើគាត់មិនបានទទួលការព្យាបាលទាន់ពេលវេលា និងត្រឹមត្រូវ។ ជំងឺនេះបង្កដោយមេរោគបាក់តេរីឈ្មោះ Salmonella enterica (typhi , Paratyphi) ។

**ក. ការចម្លងរោគ៖**

ជំងឺគ្រុនពោះវៀនឆ្លងតាមរយៈការបរិភោគទឹក ឬអាហារដែលមានផ្ទុកនូវពពួកមេរោគ Salmonella enterica (typhi ,Paratyphi) ។

**ខ. រោគសញ្ញា៖**

អ្នកជំងឺដែលកើតជំងឺនេះ មានរោគសញ្ញាដូចខាងក្រោម៖

- ក្តៅខ្លួន ដែលសីតុណ្ហភាពអាចដល់ 39C° – 40C°
- ភាពមិនស៊ីចង្វាក់គ្នារវាងកំដៅ និងជីពចរ
- អស់កម្លាំង
- ឈឺក្បាលខ្លាំង
- ចង្អោរ
- ពិបាកបន្ទោរបង់ ឬរាករូស
- មានករណីតិចតួចដែលមានសញ្ញាកន្ទួលក្រហមនៅលើស្បែក ជាពិសេសស្បែកពោះ។




**គ. ការធ្វើរោគវិនិច្ឆ័យ**

- ការសាកសួរ និងការពិនិត្យអ្នកជំងឺឲ្យបានច្បាស់លាស់ ជាជំហានដែលសំខាន់។
- ការពិនិត្យឈាម និងការបណ្តុះមេរោគដើម្បីទទួលបាននៅប្រភេទមេរោគព្រមទាំង ថ្នាំសម្លាប់មេរោគឲ្យបានត្រឹមត្រូវ និងច្បាស់លាស់។
- ការពិនិត្យលាមក ក៏មានសារប្រយោជន៍សំរាប់ការស្វែងរកប្រភេទមេរោគដែរតែយើងសង្កេតឃើញថា ការជុះរបស់មេរោគមានកម្រិតទាប។

**ឃ. វិធីសាស្ត្រនៃការព្យាបាល**

- អ្នកជំងឺចាំបាច់ត្រូវការការព្យាបាលថ្នាំអង់ទីប៊ីយូទិក (Antibiotic) សម្រាប់សម្លាប់មេរោគ Salmonella។
- រយៈពេលនៃការព្យាបាល អាស្រ័យទៅលើស្ថានភាពរបស់អ្នកជំងឺ (មិនសូវធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរ)។
- ការស្វែងរកប្រភេទមេរោគ ពិតជាមានសារៈសំខាន់សំរាប់ការព្យាបាល។

**ង. វិធីបង្ការ៖**

- បង្កើនទម្លាប់ក្នុងការធ្វើអនាម័យ ជាពិសេសលាងដៃនិងសាប៊ូក្រោយពេលបន្ទោរបង់រួច និងមុនពេលទទួលទានអាហារ។
- ត្រូវទទួលទានទឹកស្អាត និងបរិភោគចំណីអាហារដែលឆ្អិនល្អ។
- វ៉ាក់សាំងការពារមេរោគ Salmonella enterica (typhi) មានពីរប្រភេទ៖ ប្រភេទលេប និងប្រភេទចាក់សាច់ដុំ។

គេសង្កេតឃើញថាប្រសិទ្ធភាពរបស់វ៉ាក់សាំងប្រភេទនេះ អាចការពារបានត្រឹមតែ ៥០% ទៅ ៦០% តែប៉ុណ្ណោះ ដូច្នេះហើយការធ្វើអនាម័យដោយលាងដៃនិងសាប៊ូព្រមទាំងទទួលទានទឹកស្អាត ហើយអាហារដែលចម្អិនបានឆ្អិនល្អនៅតែជាការការពារដ៏ចម្បង។

"ប្រសិនលោកអ្នកមានរោគសញ្ញាដូចបានរៀបរាប់ខាងលើ សូមអញ្ជើញមកជួបជាមួយវេជ្ជបណ្ឌិតជំនាញ ដើម្បីពិគ្រោះនិងធ្វើរោគវិនិច្ឆ័យ ដែលឈានទៅរកការព្យាបាលត្រឹមត្រូវនិងប្រសិទ្ធភាព"





# តើជំងឺ ឈឹក-ឈឺចាក់ដល់ដៃ

## មានសភាពដូចម្តេចខ្លះ?

- តើរោគសញ្ញានៃការឈឹក-ឈឺដៃកើតឡើងមានអ្វីខ្លះ ?
- តើត្រូវព្យាបាលដោយវិធីណាខ្លះទើបអាចជាសះស្បើយបាន?
- តើអ្នកមានការធុញថប់ក្នុងអារម្មណ៍រាល់ថ្ងៃដែរឬទេ?
- តើអ្នកមានការរងទុក្ខវេទនាឈឺកញ្ចឹងក-ឈឺក្បាលរាល់ថ្ងៃដែរឬទេ?
- តើអ្នកឈឺកញ្ចឹងក-ស្មារាល់ថ្ងៃដែរឬទេ?
- តើអ្នកមានឈឺក្បាលប្រកាំងជាប់ជាប្រចាំដែរឬទេ?
- តើមានធ្វើទុក្ខបេះដូង ឬឈឺម្ដុំឆ្អឹងខ្នង ដែរឬទេ?

ក) ការឈឺចាប់របៀបនេះវាអាចរាលដាលពីកញ្ចឹងក-ស្មា-ដៃ និងខ្នងផ្នែកខាងលើ (ម្ដុំស្លាបប្រចៀវ) ហើយវាអាចរាលដាលឈឺដល់កែងដៃ កដៃ ម្រាមដៃទៀតផង ជួនកាលមានស្ពឹកនៅលើម្រាមទី៤ ទី៥ ឬម្រាមទី២ ទី៣ ឬឈឺក្រហាយនៅលើផ្នែកខាងក្រៅកំភួនដៃ ។

- ភាពមិនស្រណុកសុខស្រួលនៃក ស្មា ដៃ ឈឺស្ពឹកស្រពន់ ចុករោយ ដែលធ្វើឲ្យរំខានដល់ការធ្វើការងារ
- ខ្សោយកម្លាំងដៃ
- ឈឺស្ពឹក ស្រពន់ ក្រហាយដូចរលាកភ្លើង ឈឺចាក់ៗដូចមុតវត្ថុស្រួច ឈឺស្ពំពីកចាក់ទៅចុងដៃ។ ការឈឺបែបនេះវាមានបញ្ហាជាមួយការគាបសរសៃប្រសាទ នៅឆ្អឹងកងក។

សញ្ញាទាំងអស់ខាងលើនេះចាំបាច់ណាស់ដែលត្រូវទៅជួបគ្រូពេទ្យដើម្បីពិគ្រោះ និងព្យាបាល។

ខ) មូលហេតុដែលធ្វើឲ្យអាការៈខាងលើកើតឡើង គឺបណ្ដាលមកពី

- ធ្វើការងារជាប្រចាំថ្ងៃ
- ការងារការិយាល័យដែលអង្គុយយូរ ធ្វើឲ្យមានស្ត្រេស មានបញ្ហាឈឺចុករោយកញ្ចឹងក ឈឺស្មា ឈឺចង្កេះ
- ធ្លាប់គ្រេចចង្កេះ
- ដួលអុកគូទ
- លើកវត្ថុធ្ងន់ៗ
- គ្រោះថ្នាក់ចរាចរណ៍... ។ល។

គ) ការព្យាបាលក្នុងគោលការណ៍៖

១) សម្រាកឲ្យបានច្រើន ៖ វាធ្វើឲ្យយើងបន្ធូរបន្ថយនូវស្ត្រេស និងភាពតានតឹងក្នុងអារម្មណ៍បានមួយចំនួនធំ និងបន្ថយការសម្លឹងមើលច្រើនពេក។

២) ព្យាបាលដោយឱសថ ៖ ការប្រើប្រាស់ថ្នាំពេទ្យ ធ្វើឲ្យយើងបាត់ឈឺចាប់លឿនទៅតាមតម្រូវការដែលយើងចង់បានគ្រប់គ្នា ហើយវាជាផ្នែកមួយក្នុងការព្យាបាលដ៏ចាំបាច់ដើម្បីឲ្យបាត់ឈឺ និងជាសះស្បើយនៃជំងឺ។ ប៉ុន្តែអ្វីដែលធ្វើឲ្យយើងមានផលពិបាកនោះគឺ នៅពេលអស់ជាតិថ្នាំ ការឈឺកើតឡើងវិញដដែល ។

៣) ព្យាបាលដោយចលនា ៖ ជាធម្មតា អ្នកត្រូវដោះស្រាយព្យាបាលការបាត់បង់មុខងារចលនាដំបូងហើយព្យាបាលនៅ ក ស្មា ដៃ និងសន្លាក់ឆ្អឹងខ្នងផ្នែកខាងលើរបស់អ្នក ។

- ស្អំសរសៃដោយម៉ាស៊ីន Microthremy ៖ ធ្វើឲ្យបន្ធូរសាច់ដុំដែលឈឺ កន្ត្រាក់ជាប់នៅម្ដុំកញ្ចឹងក បំបាត់ភាពស្ត្រេស និងចុករោយកញ្ចឹងក។
- ព្យាបាលដោយម៉ាស៊ីនថែនឌ៍ (TENS) ៖ ដើម្បីសម្រួល និងបន្ធូរសាច់ដុំ។
- ធ្វើការបន្ធូរសាច់ដុំ និងធ្វើចលនាដោយដៃនៅម្ដុំកញ្ចឹងក ស្មា ខ្នងផ្នែកខាងលើឲ្យប្រសើរឡើងមកវិញនូវចលនាសន្លាក់ ។
- ទាញពន្លាតសាច់ដុំ និងការពន្លាតបន្ធូរដោយដៃ លើសរសៃប្រសាទដែលមានការឈឺចាប់។
- ធ្វើចលនាសន្លាក់ស្មា ស្លាបប្រចៀវឲ្យមានដំណើរការល្អឡើងវិញ។
- ទាញត្រាក់ស្បូងឆ្អឹងកងក (Traction Cervicale) ៖ ក្នុងករណីលៀនទ្រនាប់ឌីសគាបសង្កត់លើសរសៃប្រសាទដែលឈឺដល់ដៃ។









ជាទូទៅការឈឹក ឈឺដៃ អាចព្យាបាលបានដោយជោគជ័យនូវដំណាក់កាលដំបូង និងអាស្រ័យទៅលើរយៈពេលនៃការឈឺចាប់។ ជាញឹកញាប់យើងសង្ឃឹមថាវាចុះថយសញ្ញាការឈឺចាប់ជាមួយការព្យាបាល ៣ - ៥ សេអង់ដំបូង។ ករណីខ្លះទៀត វាមានការឈឺចាប់ដល់កដៃ កែងដៃ ឬដៃទាំងសងខាង យើងត្រូវការពេលវេលា និងការព្យាបាលលំអិតថែមទៀតដែលធ្វើឲ្យវាជាសះស្បើយប្រកបដោយគុណភាពជីវិត គឺអាចធ្វើការងារបានដូចធម្មតា ធ្វើសកម្មភាពប្រចាំថ្ងៃផ្សេងៗបានឡើងវិញទាំងស្រុង។

៤) បើការព្យាបាលដោយចលនាមិនបានជោគជ័យ អ្នកត្រូវទៅជួបគ្រូពេទ្យជំនាញព្យាបាលដោយវះកាត់ឆ្អឹងកងខ្នងលើបញ្ហាទ្រនាប់ឌីសឆ្អឹងកងកដែលគាបសរសៃប្រសាទ។

# គ្រោះថ្នាក់ធ្ងន់ធ្ងរនៃ ក្រួសតម្រងនោម !



បើទោះជាមានមូលហេតុផ្សេងៗគ្នានៃការកកើត ទំហំតូចឬធំ ក្រួសតម្រងនោមអាចសម្ងំនៅក្នុងខ្លួនមនុស្ស ដោយមិនបញ្ចេញជារោគសញ្ញាអ្វីទាំងអស់ដល់អ្នកជំងឺ ជាពិសេសនៅពេលដែលវាមិនទាន់ធ្វើឱ្យស្ទះដល់លំហូរនៃប្រព័ន្ធ ទឹកនោម។ នៅពេលដែលក្រួសតម្រងនោមរំកិល ឬធ្វើឲ្យស្ទះដល់ដំណើរលំហូរនៃទឹកនោម ព្រឹត្តការណ៍ពីរធំៗអាចកើតមានឡើង៖

**១) ការឈឺចាប់ខ្លាំងនៅតំបន់ចង្កេះ** ( Colique néphrétique )៖

ការឈឺចាប់នេះបណ្តាលមកពីការស្ទះភ្លាមៗនៃប្រព័ន្ធទឹកនោមផ្នែកខាងលើ (អាចខាងឆ្វេង ឬខាងស្តាំ) បណ្តាលឲ្យមានការរីកធំដោយការដក់ទឹកនោមនៅក្នុងតម្រងនោម។ ការឈឺចាប់នេះអាចនឹងធូរស្បើយទៅវិញដោយសារ៖

- ក- ការធ្លាក់ផុតពីបំពង់ទឹកនោមចូលទៅក្នុងប្លោកនោម ដោយក្រួសដែលមានទំហំតូចៗ (៣-៤មម)។
- ខ- ការបែកធ្លាយនៃប្រព័ន្ធទឹកនោមផ្នែកខាងលើ (Rupture fornix)។
- គ- ការប្រើថ្នាំបំបាត់ការឈឺចាប់។



ផ្ទៀងផ្ទាត់ចម្លើយ

Q1: ៣ Q3: ២

Q2: ២ Q4: ១

សំណួរចម្លើយ Quiz ទាក់ទងនឹងសុខភាព

ទំព័រ ០៩

**ចំណាំ៖** គ្រោះថ្នាក់ធ្ងន់ធ្ងររហូតខូចតម្រងនោម ភាគច្រើនជួបប្រទះក្នុងករណីចុងក្រោយ ដែលអ្នកជំងឺលែងមានការឈឺចាប់បន្ទាប់ពីពិសារថ្នាំ ហើយគិតថាគ្រាប់ក្រួសជ្រុះ ឬធ្លាក់បាត់។ ផ្ទុយទៅវិញក្រួសនោះអាចនៅបន្តស្ទះដោយលែងមានរោគសញ្ញាឈឺចាប់ខ្លាំងដូចពីដំបូង។ ដោយសារការស្ទះនេះ តម្រងនោមនឹងចាប់ផ្តើមខ្សោយបន្តិចម្តងៗ រហូតដល់ខូចលែងដំណើរការ។

**២) ការឈឺចាប់នៅតំបន់ចង្កេះរួមផ្សំនឹងមានការក្តៅខ្លួន** ( Pyélonéphrite aiguë )៖

គឺជាការស្ទះនៅផ្លូវបង្ហូរទឹកនោម រួមទាំងការរលាកស្រួចស្រាវដល់បំពង់ទឹកនោម និងតម្រងនោម ដែលស្ទះនោះ។
កត្តាចម្បងដែលធ្វើឲ្យមានមេរោគ ឬខ្ទុះក្នុងប្រព័ន្ធបង្ហូរទឹកនោមគឺការចាល់ ឬស្ទះទឹកនោមនៅផ្នែកណាមួយនៃប្រព័ន្ធ។ ការរលាកតម្រងនោមស្រួចស្រាវបណ្តាលមកពីការស្ទះទឹកនោម (Pyélonéphrite aiguë obstructive) ជាករណីបន្ទាន់វេជ្ជសាស្ត្រដែលអាចធ្វើឲ្យអ្នកជំងឺគ្រោះថ្នាក់រហូតដល់បាត់បង់អាយុជីវិត ប្រសិនបើមិនមានការព្យាបាលត្រឹមត្រូវ និងទាន់ពេលវេលា។

នៅមន្ទីរពេទ្យកាល់ម៉ែត យើងជួបប្រទះករណីអ្នកជំងឺធ្ងន់ធ្ងរដែលមានសញ្ញាគំរាមកំហែងដល់អាយុជីវិត ដូចករណីខាងលើ មាន ៣ ទៅ ៤ ករណីជាមធ្យមក្នុងមួយខែ។ អ្នកជំងឺទាំងនោះភាគច្រើនស្តែងចេញជាសញ្ញាដូចខាងក្រោម (Septicémie)៖

- ស្មារតីមិននឹងនរ
- សម្ពាធឈាមមិននឹងនរ (ស្រុតចុះ)
- ក្តៅខ្លួន (+/-)
- ហត់

ក្រោយការធ្វើរោគវិនិច្ឆ័យពីការរលាកតម្រងនោមស្រួចស្រាវដោយការស្ទះ ការព្យាបាលដោយថ្នាំ នៅផ្នែកសង្គ្រោះបន្ទាន់កម្រិតធ្ងន់ បូករួមទាំងការបង្ហូរទឹកនោមដែលមានមេរោគ ឬខ្ទុះទាន់ពេលវេលា គឺអាចជួយសង្គ្រោះជីវិតអ្នកជំងឺឡើងវិញបាន។

ដើម្បីការពារកុំឲ្យក្រួសតម្រងនោមផ្តល់ផលវិបាករហូតដល់ខូចតម្រងនោម ឬមហន្តរាយដល់អាយុជីវិត សូមបងប្អូនអញ្ជើញទៅពិគ្រោះយោបល់ ធ្វើរោគវិនិច្ឆ័យ និងទទួលការព្យាបាលនៅមន្ទីរពេទ្យដែលមានគ្រូពេទ្យជំនាញឯកទេសច្បាស់លាស់។

នៅមន្ទីរពេទ្យកាល់ម៉ែត មានគ្រូពេទ្យជំនាញផ្នែកវះកាត់ប្រព័ន្ធមូត្រសាស្ត្រ និងឧបករណ៍ទំនើបៗក្នុងការធ្វើរោគវិនិច្ឆ័យ ពិសេសការព្យាបាលដោយការឆ្លុះចាប់ និងបំបែកក្រួសតាមបង្ហូរនោមដោយ ឧបករណ៍ដែលមានទំហំតូច យើងអាចធ្វើការព្យាបាលក្រួសតម្រងនោមបានដោយសុវត្ថិភាព និងគ្មានការឈឺចាប់ដែលបណ្តាលមកពីការវះកាត់។



# ជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាលអាចបណ្ដាលឲ្យយើងស្លាប់ ឬធ្លាក់ខ្លួនពិការបាន (Stroke)!



យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក ចំនួននៃអ្នកកើតជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាលក្នុងមួយឆ្នាំៗ មានចំនួនប្រហែល ១៥លាននាក់ ហើយក្នុងនោះមាន ៥លាននាក់អាចស្លាប់បាន។ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល
នៅក្នុងប្រទេសកម្ពុជាយើងក៏ដូចជានៅលើសកលលោក
ក្រុមការងារជំនាញមន្ទីរពេទ្យកាល់ម៉ែតយើងខ្ញុំបាន
រៀបចំបង្កើតប្រព័ន្ធថៃទាំព្យាបាលបន្ទាន់សម្រាប់ជំងឺនេះ (Stroke Unit)។
យើងត្រូវតែស្គាល់ពីរោគសញ្ញានៃជំងឺនេះទាំងអស់គ្នា ដើម្បីឆាប់បញ្ជូនអ្នកជំងឺមកកាន់មន្ទីរពេទ្យឲ្យបានលឿនបំផុត។
រោគសញ្ញាសំខាន់ៗមាន៖

- ពិបាកនិយាយភ្លាមៗ ឬ និយាយមិនបាន
- ទន់ដៃ ជើង មួយចំហៀងភ្លាមៗ (ពាក្យខ្មែរយើងថាស្លាប់មួយចំហៀងខ្លួន)




ប្រសិនបើអ្នកជំងឺបានមកដល់មន្ទីរពេទ្យ ក្នុងថេរៈវេលា៤ម៉ោងដំបូង ក្នុងករណីស្ទះសរសៃឈាមខួរក្បាល គាត់អាចទទួលបានការព្យាបាលដោយឱសថទំនើបចុងក្រោយ (Thrombolysis) ដែលអាចរំលាយដុំកំណកឈាមនោះបាន (ប្រសិនបើអ្នកជំងឺមិនមានកត្តារំខានផ្សេងៗទៀតចំពោះការ ប្រើប្រាស់ថ្នាំនេះទេ)។
ការយឺតយ៉ាវក្នុងការព្យាបាលជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល អាចឲ្យយើងធ្លាក់ខ្លួនពិការបាន ដែលជាការខាតបង់ធំធេងណាស់ចំពោះខ្លួនយើង គ្រួសារក៏ដូចជាសង្គមជាតិយើងទាំងមូល។
តាមអង្គការសុខភាពពិភពលោក គ្រប់អ្នកជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល ត្រូវតែបានទទួលការព្យាបាលនៅក្នុងបន្ទប់ព្យាបាលបន្ទាន់នៃជំងឺនេះ (Stroke Unit) ដែលមានគ្រប់ផ្នែកជំនាញឯកទេសពាក់ព័ន្ធ ដូចជាខាងសង្គ្រោះបន្ទាន់ ខាងរូបភាពវេជ្ជសាស្ត្រ ខាងប្រសាទសាស្ត្រ សរសៃឈាមខួរក្បាល ខាងវះកាត់ប្រព័ន្ធប្រសាទ និងខាងព្យាបាលដោយចលនា។










ការអញ្ជើញមកកាន់មន្ទីរពេទ្យជាបន្ទាន់ ក្រោយលោកអ្នកមាន រោគសញ្ញាដូចរៀបរាប់ខាងលើ បច្ចេកវិទ្យាថ្មីទំនើប របស់មន្ទីរពេទ្យកាល់ម៉ែត និងការថៃទាំតាមជំនាញវិជ្ជាជីវៈ ប្រកបដោយទំនុកចិត្តខ្ពស់ គឺជាកត្តាសត្យានុម័តនៃការ កាត់បន្ថយពិការភាព ដោយសារជំងឺនេះក៏ដូចជាការកាត់បន្ថយ សេចក្តីស្លាប់ដែរ។






# ដំណោះស្រាយអាការៈឈឺក្បាល!

អាការៈឈឺក្បាល គឺតែងតែជួបជាញឹកញាប់ក្នុងជីវិតប្រចាំថ្ងៃ វាអាចជារឿងតូចតាច តែក៏អាចជារឿងគ្រោះថ្នាក់ដែរទៅតាមមូលហេតុរបស់វា។ អាការៈឈឺក្បាល ជាការឈឺចាប់ត្រង់ផ្នែកក្បាល ដោយពេលខ្លះឈឺខ្លាំងស្ទើរទ្រាំពុំបាន ឬពុំអាចប្រកបរបរការងារបាន។ វាមានមូលហេតុជាច្រើនដែលបណ្តាលឱ្យឈឺក្បាល ដែលមូលហេតុទាំង នោះអាចកំណត់ ឬស្តែងពីទីតាំង ភាពញឹកញាប់នៃការឈឺក្បាល និងរោគ សញ្ញារួមផ្សំមួយចំនួន ដែលយើងអាចដឹងបានប្រសិនបើមានការមកពិនិត្យ និងពិគ្រោះជាមួយវេជ្ជបណ្ឌិតជំនាញ។

១) តើបញ្ហាឈឺក្បាលប្រភេទណាដែលអ្នកធ្លាប់ឈឺ?

ការឈឺក្បាលមានច្រើនប្រភេទ និងច្រើនទម្រង់ ដោយខ្លះមានរយៈពេលខ្លីត្រឹមប៉ុន្មាននាទី និងខ្លះទៀតមានរយៈពេលវែងដល់រាប់ម៉ោង។

គេចែកការឈឺក្បាលជា ២ ប្រភេទធំៗ៖

- ការឈឺក្បាលដោយឯកឯង ដែលមិនរួមផ្សំនឹងជំងឺផ្សេងៗ (Céphalée primaire)
- ការឈឺក្បាលបន្ទាប់ពីការប៉ះទង្គិចក្បាល ឬជំងឺផ្សេងៗ (Céphalée secondaire)

២) តើអ្វីខ្លះជាមូលហេតុនៃការឈឺក្បាល?

ការឈឺក្បាលមួយចំនួន បណ្តាលមកពីកត្តាដែលមិនធ្ងន់ធ្ងរ ប៉ុន្តែវាអាចឲ្យឈឺក្បាលរ៉ាំរ៉ៃដែលយើងជួបជាញឹកញាប់ ហើយរំខានដល់ការងារ និងការរស់នៅប្រចាំថ្ងៃដូចជា៖

- ការឈឺក្បាលប្រកាំង
- ការឈឺសរសៃមុខ និងក្បាល
- ការរលាកឆ្អឹងច្រមុះ ឬដុះសាច់ច្រមុះ
- ការធុញថប់ (Stress) និងការថប់បារម្ភ

ប៉ុន្តែក៏មានការឈឺក្បាលមួយចំនួនបណ្តាលមកពីជំងឺធ្ងន់ធ្ងរ ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិត ដែលទាមទារឱ្យមានការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ និងឆាប់រហ័សដូចជា៖

- ជំងឺរលាកស្រោមខួរក្បាល
- ការហូរឈាមក្នុងស្រោមខួរក្បាល
- ការគៀត ឬបែកសរសៃឈាមខួរក្បាល (Stroke)
- ដុំសាច់ក្នុងខួរក្បាល ឬខ្ទុះក្នុងខួរក្បាលជាដើម។

៣) តើយើងត្រូវធ្វើដូចម្តេចដើម្បីដឹងមូលហេតុនៃការឈឺក្បាល?

ចំពោះការធ្វើរោគវិនិច្ឆ័យ ជាទូទៅតែងតែពិបាកខ្លះ វាទាមទារឱ្យមានការសាកសួរ និងពិនិត្យយ៉ាងយកចិត្តទុកដាក់ហើយល្អិតល្អន់ពីវេជ្ជបណ្ឌិតឯកទេស រួមផ្សំជាមួយការធ្វើតេស្តមួយចំនួនដែលមាននៅមន្ទីរពេទ្យ ជាមួយស្តង់ដាខ្ពស់ក្នុងការ៖

- ធ្វើតេស្តឈាម
- រុករកដោយម៉ាស៊ីនស្កេនខួរក្បាល និងម៉ាស៊ីន អឹម អរ អាយ (MRI)
- វាស់ប្រព័ន្ធចរន្តខួរក្បាលដោយម៉ាស៊ីន EEG ជាដើម។

៤) តើយើងត្រូវធ្វើដូចម្តេចប្រសិនបើឈឺក្បាល?

ការព្យាបាលបញ្ហាឈឺក្បាលមានច្រើនមធ្យោបាយ និងខុសគ្នាទៅតាមមូលហេតុនៃអាការៈឈឺក្បាលនោះ។ មានតែការមកពិគ្រោះជាមួយគ្រូពេទ្យជំនាញ និងពិនិត្យនៅមន្ទីរពេទ្យតែប៉ុណ្ណោះ ដែលអាចឱ្យយើងដឹងពីមូលហេតុច្បាស់លាស់ដើម្បីទទួលបាននូវការព្យាបាលមួយដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាព។

ចំណាំ៖ សូមជៀសវាងការទៅផ្សំថ្នាំលេបនៅតាមឱសថស្ថាននានា ដោយមិនបានឆ្លងកាត់ការពិគ្រោះជំងឺជាមួយគ្រូពេទ្យជំនាញដើម្បីជៀសវាងការប៉ះពាល់សុខភាពធ្ងន់ធ្ងរ ឬការយឺតយ៉ាវដែលនាំឱ្យមានគ្រោះថ្នាក់ដល់ជីវិតជាយថាហេតុ។

ប្រសិនបើមានអាការៈឈឺក្បាល សូមប្រញាប់មកជួបជាមួយក្រុមគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យកាល់ម៉ែត ដែលត្រៀមខ្លួនជាស្រេចដើម្បីពិនិត្យពិគ្រោះផ្តល់អនុសាសន៍លម្អិត និងដោយស៊ីជម្រៅអំពីបញ្ហាសុខភាពរបស់លោកអ្នក។

" សូមប្រុងប្រយ័ត្នចំពោះអាការៈឈឺក្បាល និងស្វែងរកការព្យាបាលបានត្រឹមត្រូវ និងឆាប់រហ័ស ដែលអាចឱ្យយើងការពារអាយុជីវិតបានប្រាកដដូចពាក្យស្លោកប្រហែសបាត់ ប្រយ័ត្នគង់។ "








# ជំងឺស្ទះសរសៃវ៉ែនខួរក្បាល!

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង៦ល្ងាចបន្ទាប់ពីត្រឡប់ពីធ្វើការមកដល់ផ្ទះ ប្អូនប្រុស យុន សារិទ្ធិ មានអាការៈឈឺក្បាល អស់កម្លាំងល្ហិតល្ហៃ រួចបានចូលទៅបន្ទប់ទឹក ស្រាប់តែមានអការៈប្រកាច់ និងបាត់បង់ស្មារតី។ អការៈដូចនេះតែងកើតមានឡើង៦ដងក្នុងមួយថ្ងៃ ដោយមានរោគសញ្ញាបន្ថែមដូចជាខ្សោយកម្លាំង និងស្ពឹកដៃជើងមួយចំហៀងខាងស្តាំលើកមិនរួច។
ដោយដឹងខ្លួនមានស្ថានភាពមិនស្រួល ប្អូនសារិទ្ធិ បានហៅមិត្តភ័ក្រអោយជូនទៅពិនិត្យនៅមន្ទីរឯកជនដែលនៅជិតផ្ទះ។
ដោយស្ថានភាពនៃជំងឺមានសភាពធ្ងន់ធ្ងរ គ្រូពេទ្យបានសម្រេចបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យរដ្ឋមួយនិងបានទទួលការព្យាបាល ប៉ុន្តែដោយសារឧបករណ៍មិនគ្រប់គ្រាន់ ក៏បានបញ្ជូនមកកាន់មន្ទីរពេទ្យកាល់ម៉ែតដើម្បីធ្វើការសង្គ្រោះ។ អ្នកជំងឺត្រូវបានបញ្ជូនចូលមកផ្នែកសង្គ្រោះបន្ទាន់ និងបន្ទាប់មកត្រូវបានបញ្ជូនមកសម្រាកព្យាបាលនៅផ្នែកប្រសាទសាស្ត្រនៃមន្ទីរពេទ្យកាល់ម៉ែត។

ក្រុមគ្រូពេទ្យឯកទេស បានប្រជុំគ្នាធ្វើការពិនិត្យគ្លីនិក និងអមគ្លីនិក ជាពិសេសគឺបានបញ្ជូនអ្នកជំងឺធ្វើការស្កេនខួរក្បាល ដោយមានការចាក់ថ្នាំជំនួយ និងស្កេនដោយម៉ាស៊ីនស្កេនទំនើប(Multibarette)ជាជំនួយផងនោះ ក្រុមគ្រូពេទ្យឯកទេសប្រសាទសាស្ត្រ កំណត់បានរោគវិនិច្ឆ័យច្បាស់លាស់ជាជំងឺស្ទះសរសៃវ៉ែនខួរក្បាល (Thrombophlébite Cérébrale)។ ក្រោមការពិនិត្យព្យាបាល និងយកចិត្តទុកដាក់ខ្ពស់ពីក្រុមគ្រូពេទ្យឯកទេសប្រសាទសាស្ត្រ តាមលក្ខណៈបច្ចេកទេសច្បាស់លាស់ក្នុងរយៈពេល ១៤ថ្ងៃ រួចមកស្ថានភាព អ្នកជំងឺមានការធូរស្រាលយ៉ាងឆាប់រហ័ស ដោយអ្នកជំងឺលែងមានការប្រកាច់ទៀតហើយព្រមទាំងមានកម្លាំងដៃជើងប្រសើរឡើងវិញ ហើយអ្នកជំងឺអាចក្រោកឈរ និងដើរដោយខ្លួនឯងបាន។ មិនត្រឹមតែទទួលការព្យាបាលដោយក្រុមគ្រូពេទ្យឯកទេស អ្នកជំងឺក៏ត្រូវទទួលបានការព្យាបាលដោយចលនាបន្ថែមផងដែរ ដើម្បីជួយឲ្យស្ថានភាពអ្នកជំងឺកាន់តែឆាប់ជាសះស្បើយ និងអាចត្រលប់ចេញពីមន្ទីរពេទ្យវិញនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧។





អ្នកជំងឺ និងក្រុមគ្រួសារមានការសប្បាយរីករាយយ៉ាងខ្លាំងចំពោះសេវាព្យាបាលដ៏មានប្រសិទ្ធភាពរបស់មន្ទីរពេទ្យកាល់ម៉ែតដែលមានក្រុមគ្រូពេទ្យឯកទេសជាច្រើនជំនាញជាពិសេសក្រុមគ្រូពេទ្យឯកទេសផ្នែកប្រសាទសាស្ត្រ ព្រមទាំងមានបរិក្ខារទំនើបដែលអាចសង្គ្រោះ ជីវិតប្អូនប្រុស យុន សារិទ្ធិ និងជួយឲ្យគាត់រួចផុតពីពិការភាពក្នុងពេលដែលម្តាយអ្នកជំងឺមានភាពអស់សង្ឃឹមទៅហើយនៅពេលឃើញស្ថានភាពនៃជំងឺរបស់កូនប្រុសពីដំបូងនោះ។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមគ្រួសារអ្នកជំងឺបានកោតសរសើរអំពីសមត្ថភាពរបស់ក្រុមគ្រូពេទ្យ និងបុគ្គលិកទាំងអស់ដែលប្រកបដោយភាពរួសរាយរាក់ទាក់ និងមានការយកចិត្តទុកដាក់ខ្ពស់ទៅលើអ្នកជំងឺដែលផ្ទុយពីពាក្យចចាមអារាមខាងក្រៅ ពោលគឺមន្ទីរពេទ្យកាល់ម៉ែតទទួលព្យាបាលអ្នកជំងឺដោយគ្មានរើសអើង។
ប្អូនប្រុស សារិទ្ធិ និងក្រុមគ្រួសារសូមអំពាវនាវដល់អ្នកជំងឺដែលមានអាការៈដូចគាត់សូមប្រញាប់រួសរាន់មកទទួលការពិនិត្យព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែតជាមួយក្រុមគ្រូពេទ្យឯកទេស និងមានសម្ភារៈបរិក្ខារទំនើបជំនួយក្នុងការធ្វើរោគវិនិច្ឆ័យយ៉ាងត្រឹមត្រូវ និងធ្វើការព្យាបាលបានទាន់ពេលវេលា ព្រមទាំងទទួលបានប្រសិទ្ធភាពខ្ពស់។

# សំណួរចម្លើយ Quiz ទាក់ទងនឹងសុខភាព



Q1. អ្នកជំងឺម្នាក់ឈឺស្មារ៉ាំរ៉ៃ រយៈពេល ៥ខែ ដោយលើកដៃឡើងលើ សិតសក់មិនបាន តើគាត់ត្រូវព្យាបាលដោយវិធីណា ?

១. ព្យាបាលដោយថ្នាំពេទ្យ
២. ព្យាបាលដោយវះកាត់ លើសរសៃស្មា
៣. ព្យាបាលដោយចលនា ដើម្បីពត់ទាញពន្លាតគន្លងសន្លាក់

Q2.ចំណុចមួយណាដែលជំងឺរលាកថ្លើមដោយមេរោគប្រភេទ បេ មិនចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត?

១. ការប៉ះពាល់ឈាមអ្នកជំងឺថ្លើមប្រភេទ បេ
២. ការប្រស្រ័យទាក់ទង និងហូបបាយជុំគ្នា
៣. ការរួមភេទដោយមិនបានការពារត្រឹមត្រូវ

Q3. តើជំងឺផ្តាសាយត្រូវប្រើថ្នាំផ្សះ (អង់ទីប៊ីយូទិក) ដែរឬទេ?

១. ពុំចាំបាច់ឡើយព្រោះវាបង្កឡើងដោយវីរុស
២. ត្រូវប្រើ

Q4.សន្ទស្សន៍ជាតិស្ករនៅក្នុងអាហារចែកចេញជាបីប្រភេទទៅតាមកម្រិតរបស់អាហារដូចនេះអ្នកជំងឺទឹកនោមផ្អែមគួរជៀសវាងទទួលទាននូវអាហារដែលមានសន្ទស្សន៍ជាតិស្ករបែបណា?

១- សន្ទស្សន៍ជាតិស្ករទាប
២- សន្ទស្សន៍ជាតិស្ករមធ្យម
៣- សន្ទស្សន៍ជាតិស្ករខ្ពស់



សូមមេត្តាផ្ទៀងផ្ទាត់ចម្លើយនៅទំព័រ ៥



ឧបត្ថម្ភដោយ

លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧
អ៊ីម៉ែល: hospital@calmette.gov.kh, វេបសាយ: www.calmette.gov.kh
ហ្វេសប៊ុក: www.facebook.com/calmette.gov.kh

ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត
ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត
ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត